


ទិតសារ
៣ .

# វគ្គទី ១

# កាំភ្លើងបង្កឿង

ម៉ោងប្រាំមួយល្ងាចពូជិមដាក់ម៉ូយចុះនៅភ្លើងស្តុបពេទ្យចិនហើយក៏ម្នីម្នាធាក់ស៊ីក្លូទៅផ្ទះឯពេទ្យឈោក សង្ឃ ។ មុននិងទៅដល់ផ្ទះ គាត់ឆៀងចូលដាក់ ១ពែងសិននៅតៀមយាយម៉ាប់មាត់ ផ្លូវចូលផ្ទះគាត់ ។

ពូជិមធាក់ស៊ីក្លូចូលដល់មាត់ទ្វារផ្ទះតែម្តង ។



KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង គាំទ្រសិល្បៈអក្សរសាស្ត្រខ្មែរ

មីងសៅឃើញពូជិមចុះពីស៊ីក្លូរាងទ្រេត ក៏ដឹងស្រេចមិនបាច់សួរ ទទួលស៊ីក្លូពីប្ដីគាត់ រុញយកទៅដាក់ក្បៀនផ្ទះ ។

ពូប្រាសដេកឈឺគ្រែ សំយុងជើងមកក្រោមដូចជាអស់កម្លាំងខ្លាំងណាស់ ។ មីងទុកដាក់ស៊ីក្លូចាក់សោររួចរាល់ហើយ ក៏ជួនជាក្រឡេកភ្នែកទៅឃើញកញ្ចប់អ្វីម្យ៉ាងរុំក្រណាត់កន្សែងពោះគោ នៅក្បៀនពូកស៊ីក្លូ ក៏ភ្ញាក់យកដៃទៅកាន់ឈីករបស់នោះមកមើលទើបដឹងថាដូចជាមានវត្ថុ អ្វីមួយរាងធ្ងន់ រុំក្រណាត់កន្សែងពីក្រៅ ។

មីងសៅស្រែកសួរពូជឹមថា ៖

-ឪវ៉ា ! ឯងបានរបស់ស្អីហ្នឹងយកមកដាក់ឈើស៊ីក្លូ ?

ពូជិមភ្ញាក់ព្រើត ក្រោកអង្គុយរើតមើលមកប្រពន្ធគាត់ទាំងងឿងឆ្ងល់

-របស់ស្អីទៅ ? ឯងលាមើលមើល៍ !

ពីរនាក់ប្ដីប្រពន្ធ ក៏យករបស់នោះមកលាមើល ឃើញកាំភ្លើងខ្លី១ដើមមានស្នាមប្រលាក់ឈាមផង ។

គ្រាន់តែឃើញកាំភ្លើង ពូនិងមីងភ័យញ័ររន្ធត់ ធ្លាក់កាំភ្លើងនោះពី ដៃទៅដីក្ដុក ។ មីងខ្លាចឈាម ពូខ្លាចកាំភ្លើង។ទាំងពីរនាក់មិនដែលបានកាន់កាំភ្លើងផ្ទាល់ដៃម្ដងណាឡើយ ។

មីងសៅនិយាយញ័រមាត់ទៅកាន់ពូជិម :

-ឪវ៉ា ហេតុអីក៏ឯងយករបស់អីចឹងៗ មកចូលផ្ទះ ?

-ខ្ញុំមិនដឹងទេ !មិនដឹងអ្នកណាយកមកដាក់ឈើស៊ីក្លូយើងទេ !ពូជិមនិយាយទាំងមុខស្លាំង សម្លឹងមើលកាំភ្លើងក្នុងខួរក្បាលគាត់កំពុង គិតថាតើមានម៉ូយណាខ្លះជិះស៊ីក្លូគាត់ពេលរសៀលនេះ។ គិតមួយសន្ទុះទើបគាត់លាន់មាត់ថា ៖





-នឹកឃើញហើយ គឺម៉ូយម្នាក់ចុងក្រោយគេ ដែលគាត់ជិះយកទៅដាក់មុំពេទ្យចិននោះហើយ ជាម្ចាស់កាំភ្លើងនេះ ។ ព្រោះអ្នកជិះនោះឃើញមានរបួសនៅដៃផង ។ ប៉ុន្តែគ្រាន់តែដឹងកន្លែងម៉ូយនោះចុះមិនដឹងផ្ទះគេនៅឯណាទេ ។

មីងស្ទុះទៅបិតទ្វាផ្ទះហើយពិគ្រោះជាមួយពូថា ៖

-នែឪវ៉ា តាមខ្ញុំយល់កាំភ្លើងនេះជាកាំភ្លើងរបស់ចោរហើយ ព្រោះមានប្រលាក់ឈាមផង ទំនងជាគេបាញ់វាត្រូវហើយវារត់គេច រួចយកកាំភ្លើងមកប្លុងចោលឈើស៊ីក្លូឯង !

-បែបអញ្ចឹងមែនម៉ែវ៉ា ! ព្រោះអ្នកជិះចុងក្រោយនោះ វាមានសភាពប្រញាប់

ប្រញាល់ណាស់ ហើយមានរបួសដៃ ខំយកដៃម្ខាងខ្ទប់ឈាម បង្ខំអោយខ្ញុំធាក់ស៊ីក្លូ អោយឆាប់ដល់គោលដៅ ហើយវាហុចលុយមក ខ្ញុំក្រដាស់ពីរពាន់មួយសន្លឹក ថាមិនបាច់អាប់ទេ ។

ពីរនាក់ប្តីប្រពន្ធ អង្គុយចោងហោង ពីមុខកាំភ្លើង មីងសៅបន្តរ សំដី :

-ឥឡូវឪវាឯងកុំគិតច្រើន ប្រញាប់យកវាទៅបោះចោលឯណាឯ ណីវិញទៅ

-ទៅយ៉ាងម៉េច ? នៅភ្លឺនៅឡើយ ឈាតែប៉ូលីសឃើញមិនរឺវរហើយ !

-មែនឪវា ចាំយប់ងងឹតបន្តិចចាំឯងយកវាទៅបោះចោល

-យកទៅបោះចោលទីណាទៅម៉ែវា ?

មីងគិតមួយសន្ទុះបន្តឃោបល់ថា :

-មិនបាច់យកទៅណាឆ្ងាយទេ យកវាទៅបោះចោលក្រោយឃ្លាំងក្បែរផ្ទះយើងនៅទៅ ! កន្លែងហ្នុងមានសំរាម មានគំនរឡាំងឈើច្រើនណាស់ ។

-អើមែនឯងនិយាយត្រូវ ចាំយប់បន្តិចយើងយកអាដែកចង្រៃនេះទៅបោះចោលទីនោះ ។

ម៉ោង ៧កន្លះយប់ ពូជិមហូបបាយរួចរាល់ហើយអោបកាំភ្លើង លាក់ក្នុងអាវដើរសសៀរក្បែររបងខាងក្រោយឃ្លាំង ដែលនៅជាប់ផ្ទះគាត់ ។ ពូជំទើតជើងអើតមើលទៅក្នុងរបងឃើញស្ងាត់ល្អ ។ ទីនោះមានបង្គន់មួយនិងគំនរសំរាម គំនរសំបកឡាំងគរចោលពាសពេញ ។ មើល ឆ្វេងស្តាំឃើញស្ងាត់ល្អ ពូលើកកាំភ្លើងដែលរុំក្រណាត់កន្សែងនោះគ្រវែងចូលទៅក្នុងរបងតម្រង់គំនរសំរាម ។ តែដោយគាត់ប្រញាប់ពេកគ្រវែងទៅប៉ះចំជញ្ជាំងបង្គន់ ដែលបិតបាំងដោយបន្ទះសាំងកាសី ឮសូរ លាន់ប្រាវ !។ ពូជិមរត់ប្រញាប់ត្រឡប់ចូលផ្ទះ បិតទ្វារសំងំដេកពីរនាក់ប្តីប្រពន្ធគាត់ស្ងាត់ច្រៀប ។

តាមពិត ពេលដែលពូជិម គ្រវែងកាំភ្លើងទៅប៉ះជញ្ជាំងបង្គន់នោះ សូរលាន់



ប្រាវបានធ្វើអោយនាយសាវ៉ាន់ឆ្មាំឃ្លាំងដែលកំពុងអង្គុយបត់ជើងធំក្នុងបង្គន់នោះភ្ញាក់ងាច់ភារកិច្ច ប្រញាប់ស្ទុះចេញមកក្រៅអើតរកមើលអាណា ដើងល្អលេងគប់បង្គន់អញកំពុងបត់ជើង ? ។ នាយបញ្ចាំងពិលមើលសព្វគ្រប់ ពុំឃើញមានមនុស្សសោះ ប៉ុន្តែពន្លឺពិលរបស់នាយ បានបញ្ចាំងចំកញ្ចប់សមួយនៅក្បែរបង្គន់ ។ សាវ៉ាន់គិតថា ៖

-ប្រហែលជាកញ្ចប់នេះហើយ ដែលអ្នកណាគេនោះចោលមកអម្បាញ់មិញ ។ នាយអោនរើសកញ្ចប់កន្សែងនោះមកលាមើល ក៏ភ្ញាក់បើកភ្នែកក្រឡេតឃើ ! កាំភ្លើងទេតើ !



នាយពន្លត់ភ្លើងពិល ។ អង្គុយចុះស្ទាបកាំភ្លើងក្នុងទីងងឹតហើយគិតថាអ្នកណាទៅហ៊ាន យកកាំភ្លើងមកបោះចោល ? មនុស្សល្អ ឬមនុស្សអាក្រក់ ? មានរឿងអីទៅបានជាគេយកវាមកបោះចោលទីនេះ ? ។ រាល់ថ្ងៃវិទ្យុ ទូរស្សន៍ បានអានប្រកាសរបស់រាជរដ្ឋា

ភិបាលហាមមិនអោយប្រើអាវុធជាតិផ្ទុះខុសច្បាប់ ។ ប្រហែលជាម្ចាស់កាំភ្លើងនេះព្ស្ទួរប្រកាសនេះភ័យខ្លាចមានទោសក៏យកមកចោលទីនេះទេដឹង ?។បើគេយកមកបោះចោលហើយខ្ញុំបែជារើសយកមកកាន់ផ្ទះ ថៃឆ្ប៉ូលីសមក ឃើញមិនវីវរហើយ ?។ ប៉ុន្តែ...កាំភ្លើងនេះវាជាលាភរបស់ខ្ញុំក៏ថាបាន !ព្រោះវាក៏មាន តំលៃជាប្រាក់ដែរតើ ! បើលក់វា យ៉ាងតិចក៏បានប្រាក់៥០ ដុល្លាដែរ !ប្រាក់ប៉ុននេះម្ចាស់ថ្លៃអើយទៅរកឯណាបានងាយៗ ? បើខ្ញុំយកវាលាក់ទុកសិន ហើយទៅរកម៉ូយមកទិញវា ក៏ល្អដែរ ! ទេ កុំអី ! យកវាទៅ ប្រគល់អោយនគរបាលទៅល្អជាង ! ប្រគល់អោយនគរបាល ? ស្រួលមិនស្រួលនគរបាល ចោទថាឯងបានកាំភ្លើងពីណាមក ? បើឆ្លើយរួចស្រួលមិនអីទេ ចុះបើឆ្លើយរបៀបអិរុមិនជាប់ខ្នោះ ?។ សាវ៉ាន់ពិចារណាចោទ សួរចុះឡើងតែម្នាក់ឯង ទីបំផុតក៏សំរេចចិត្តយកកាំភ្លើង នេះទៅលាក់ទុកក្នុងឡាំងឈើមួយសិនព្រឹកស្អែកចាំគិតទៀត ។

នាយដើរត្រលប់ទៅរោងសំរាប់ស្នាក់នៅរបស់ពួកឆ្មាំឃ្លាំង រួចឡើងទៅដេក ។ ពូឈុំមេឆ្មាំឃ្លាំងឃើញសាវ៉ាន់មិននិយាយស្តីប្រាសខ្លួនដេកដូចនោះក៏សួរថា ៖

-សាវ៉ាន់ឯងឈឺពោះឬ ?

-អត់ទេលោកមា

-ម៉េចបានឯងបត់ជើងយូរម្ល៉េះ ?

-បាទលោកមា គ្រាន់តែរាគបន្តិចបន្តួច

-អើ បើឈឺពោះរាគលេបអាស្ពារីន ១គ្រាប់ទៅ ថ្នាំនៅក្បាលដំណេកអញ !

-ខ្ញុំឈឺពោះរាគ អោយលេបអាស្ពារីនម៉េចត្រូវលោកមា !

-អើបើមិនលេបថ្នាំទេ ឯងអោយនាងខ្លាចចុងភៅវាកោសខ្យល់ឱ្យទៅ !



-បងម៉ាចមិនកោសអោយខ្ញុំទេ ព្រោះព្រឹកមិញខ្ញុំឈ្លោះជាមួយគាត់

-ឯងនេះចោលម្សៀតណាស់ ដើរតែទាស់ជាមួយគេសឹងគ្រប់គ្នា ។

សំដីពូឈុំចុងក្រោយ ធ្វើអោយសាវ៉ាន់ឈប់និយាយតជាមួយពូតទៅទៀត ។ សាវ៉ាន់ក៏បង្វែរអារម្មណ៍ ទៅរកកាំភ្លើងខ្លី ដែលគេលាក់ទុកក្នុងឡាំងឈើក្រោយឃ្លាំង...បើខ្ញុំលក់កាំភ្លើងនេះបានប្រាក់ ៥០ដុល្លា ខ្ញុំយកលុយនេះទៅទិញជញ្ជៀនមួយវង់ទុកអោយអូនណេតពាក់ពេលបុណ្យភ្ជុំនេះ ។ ប៉ុន្តែខ្ញុំមិនមែនយកទៅអោយនាងត្រង់



ព្រោះនោះទេអោយប្រញាប់ពេក ចិញ្ចៀនជាអំណោយរបស់ខ្ញុំចំពោះនាង វានិងគ្មាន

ពំលែសោះឡើយ ។ ខ្ញុំត្រូវចេះធ្វើអោយនាងភ្ញាក់ផ្អើល ! ដូចជាអោយនាងបិទភ្នែក
ហើយទាយ " អូនណែតទាយទៅមើល៍ ! បងបានអីអោយអូន ឯង ?" ហើយខ្ញុំនិ
យកដៃនាងមកកាន់ថ្នមៗ ហើយខ្ញុំស៊កចិញ្ចៀននៅ ម្រាមដៃទីបួនរបស់នាង"បានហើយ
អូនបើកភ្នែកមើលមើល៍ !" " អ៊ូយបងសារ៉ាន់ ! បងបានចិញ្ចៀននេះពីណាមក ? ព
ណាស់បង ! បងបានប្រាក់ពីណាទិញអោយខ្ញុំច្រើនម្ល៉េះ ? " "របស់នេះវាមិនជាថ្លៃ
ប៉ុន្មានទេអូន ! តែវាបញ្ជាក់នូវទឹកចិត្តរបស់បង ចំពោះអូនណាំ ហើយនេះប្រាក់ ៥ដុល្
ទៀតបងអោយអូនទុកចាយពេលបុណ្យភ្ជុំ !" " បងសារ៉ាន់បងចិត្តល្អណាស់បងឥឡូ
ចាយសុទ្ធតែដុល្លាខ្ញុំសុំអរគុណបងហើយ ! ខ្ញុំអត់មានវត្ថុអ្វីជូនបងវិញទេ ! "" មិនអី
អូនបងចង់ឃើញតែអូនសប្បាយចិត្ត ប៉ុណ្ណោះបងអរណាស់ហើយបងគ្មានចង់បាន
ក្រៅពីនេះទៀតទេ "។
ហេតុតែនាងអររំភើបពេកណែតចាប់ដៃខ្ញុំច្របាច់យ៉ាងថ្នមៗ ខ្ញុំខំទប់ខ្លួននិងចង្វាក់បេះ
ដូងខ្ញុំដែលកំពុងរំភើបណោតកញ្ចោងអស់ទំហឹង ។

ហើយក៏ស្រាប់តែ គ្រឹមៗ គ្រឹមៗ....

ស្នូរផ្គរលាន់លាយនិងសម្លេងភ្លៀងធ្លាក់ប្រាវៗ.......នាយសារ៉ាន់ភ្ញាក់ដាច់ក
ស្រមៃ ។ខ្យល់និងភ្លៀងបក់បោកយ៉ាងខ្លាំង តែនាយសារ៉ាន់ឥតរវីរវល់អ្វីឡើយគេសំរ
ដេកទាំងមុខញញឹម ។

នៅឯផ្ទះពូជិមឯណោះ មីងសៅភ្ញាក់ក្រោកទៅយកចានឆ្នាំង កាធុនទឹកតូច
មកដាក់ត្រង់ទឹកភ្លៀងដែលលិចពីដំបូល ។ ស្នូរសំឡទឹកភ្លៀងស្រក់លើចានឆ្នាំង លាយ
និងសម្លេងហ៊ឹងយំក្នុងប្រឡាយទឹកស្អុយក្បែរផ្ទះ បង្កើតជាតន្ត្រីយ៉ាងសាំត្រចៀក មួ
ឡើង ។មីងនិងពូអង្គុយត្របោមក្បាលជង្គង់ក្នុងទីងងឹត ព្រោះអំពូលភ្លើង ៦តឹក រប
គាត់ត្រូវខ្យល់បក់ ខ្លាំងអម្បាញ់មិញដាច់ខ្សែរលត់បាត់សូន្យឈឹងទៅហើយ ។



ផ្ទះស្លឹកនេះឈ្មោះតែផ្ទះប៉ុណ្ណោះ តែជញ្ជាំងធ្លុះធ្លាយសាចទឹកភ្លៀងចូលដូចនៅ
កណ្ដាលវាល ។ ទ្រាំមិនបានមីងក៏អោយយោបល់ពូជិមថា ៖

-ឪវ៉ា ! ជញ្ជាំងក្បាលដំណេកយើងនេះធ្លុះធ្លាយខ្លាំងណាស់ ព្រឹកស្អែកខ្ញុំចង់
អោយឪវ៉ាឯង ទៅស្នើសុំចែកសំបកឡាំងឈើគេខ្លះនៅឯ ឃ្លាំងក្បែរផ្ទះយើងយកមក
ប៉ះប៉ូវជញ្ជាំងនេះអោយគត់មត់នឹងទឹកភ្លៀង បន្តិចទៅណាំ ឪវ៉ា ។

-មិនអីទេម៉ែវ៉ា ចាំស្អែកខ្ញុំចូលទៅរកលោកបងឈុំដែលធ្លាប់លេងអុកជាមួយ
គ្នាលោកបងឈុំចិត្តល្អណាស់ មិនលែងគាត់ចែកអោយយើងខ្លះទេ ។

១ម៉ោងក្រោយមក ខ្យល់ និង ភ្លៀងក៏ស្ងប់ ។ ពូនិងមីង លង់លក់ក្នុងដំណេក
ផ្ទើសភ្លី ។



ភ្លឺស្រាងៗ សាវ៉ាន់ភ្ញាក់ពីដំណេកម្ដីម្ដាដើរទៅបង្គន់ក្រោយឃ្លាំងគេសម្លឹងមើល នាយអាយឃើញស្វាត់ ក៏យកដៃរាវក្នុងឡាំងស្ដាបរកកាំភ្លើងរបស់គេ ឃើញវានៅសំងំ ដេកយ៉ាងស្រួល ក្នុងកន្លែងដែលគេបានលាក់ ទុក ។ គេញញឹម ហើយពោលថា " ឯង នៅទីនេះសិនចុះណាំ ចាំអញទៅ រកម៉្ហូយមកទិញឯង "។

សាវ៉ាន់ស្លៀកពាក់ប្រញាប់ប្រញាល់ . ពូឈុំដែលកំពុងអង្គុយលុបមុខក្បែរនោះ ឃើញសាវ៉ាន់ស្លៀកពាក់បំរុងចេញទៅណាទាំងព្រលឹម នឹកឆ្ងល់ក៏សួរថា ៖

-សាវ៉ាន់ ឯងស្លៀកពាក់ទៅណាហ្នឹង ទាំងព្រលឹមអុរ ?

សាវ៉ាន់ឆ្លើយតបវិញថា ៖

-លោកមា ! ខ្ញុំសុំច្បាប់ទៅកាត់សក់១ម៉ោងខ្ញុំមកវិញហើយ

-កាត់សក់ ? ហាងកាត់សក់ឯណាវាបើកទាំងព្រលឹមអុរដូច្នេះ ? ឯងកុហក់ អញទេដឹង ? ឬមួយឯងមានការទៅណាផ្សេង ?

-ខ្ញុំអត់កុហក់លោកមាទេ ខ្ញុំមានស្គាល់ពួកម៉ាកម្នាក់បើកតូបកាត់សក់ ខ្ញុំពឹងគេ អោយជួយកាត់អោយមុនគេព្រោះខ្ញុំប្រញាប់ត្រលប់មកវិញជួយធ្វើការលោកមាពីព្រឹក។

-អើ ! ទៅចុះ ! ព្រឹកនេះ ឡានមកដឹកសំភារៈយកទៅបោះអោយហាង ឯង ត្រូវប្រញាប់មកជួយជញ្ជូនអីវ៉ាន់គេ ឮទេ !

-បាទលោកមា !

សាវ៉ាន់ បានច្បាប់ពីពូឈុំហើយ ម្ដីម្ដាដើរទៅហៅម៉ូតូឌុបជិះចេញ ទៅផ្សារទឹក ថ្លាបាត់ទៅ ។

ដូចគំរោងដែលបានគិតពីល្ងាច ពូជិមដើរចូលទៅក្នុងឃ្លាំងភ្នែករំពៃរកមើល



ពូឈុំក៏ប្រទះឃើញគាត់កំពុងអង្គុយពិសាបបរ និងពងទាប្រៃម្នាក់ឯង ។

ឃើញពូជិមដើរសំដៅមក ពូឈុំស្រែកហៅជាការគួរសម

-ប្អូនជិមមកហូបបបរជាមួយខ្ញុំ !

-បាទអរគុណហើយលោកបង អញ្ជើញពិសាចុះ ខ្ញុំព្រឹកអីចឹងបានតែកាហ្វេទេ !

-កាហ្វេក៏មានដែរ អញ្ជើញអង្គុយសិនមក ( ពូឈុំហុចកាហ្វេ ១ពែងជារបស់ គាត់ទៅពូជិម ) ប្អូនជិមមកទាំងព្រលឹមមាន ការអីដែរ ?

-លោកបងអើយ ខ្ញុំមានការសំខាន់គួរសមដែរ គឺខ្ញុំចង់សុំចែកសំបកឡាំងដែល គរចោលក្រោយឃ្លាំង បានមួយចំនួនយកទៅធ្វើជញ្ជាំងផ្ទះ ព្រោះភ្លៀងសាចសម្បើម ណាស់ លោកបងគិតតួរថ្លៃថ្នូរខ្លះទៅចុះណាំ ។

-រឿងប៉ុណ្ណឹង ខ្ញុំស្មានតែមានការអីធំដុំ នៅជិតខាងគ្នាអីចឹងចាំបាច់លក់ដូរអ្វី សព្វបើសំបកឡាំងចាស់ៗ ហ្នឹងនោះ ។ ថៅកែខ្ញុំក៏ គាត់មិនទៅកំណាញ់ អីត្រឹមម៉ា សំបកឡាំងនោះដែរ ។ ប្អូនជិមឯងទៅយកស៊ីក្លូមកដឹកយកខ្លះទៅណាំ ។

ពូជិមត្រេកអរណាស់ ក៏ម្ដីម្ដាលាពូឈុំទៅផ្ទះយកស៊ីក្លូមកដឹកយកសំបកឡាំង បានបួនដប់ឡាំងយកទៅគរទុកក្នុងផ្ទះគាត់ ។

ពីរនាក់ប្ដីប្រពន្ធ ក៏ចាប់ផ្ដើមគាស់ឡាំងយកក្ដារតំរៀបទុកយ៉ាងល្អ ។

ប៉ុន្តែ កំពុងតែគាស់ឡាំងទី៣ ស្រាប់តែមានកញ្ចប់អ្វីម្យ៉ាង ធ្លាក់ចេញពីក្នុង ឡាំងមក ។

ពូនិងមីងភ្ញាក់ សម្លឹងមើលរបស់នោះ ទើបភ្ញាត់មាត់ទាំងពីរនាក់ថា កាំភ្លើង ! អាដែកចង្រៃនោះវាមកវិញហើយ !



រក្សាសិទ្ធិគ្រប់យ៉ាង





-យី ម៉េចអញ្ជើងឪវា ? ឯងយកវាទៅបោះចោលកន្លែងណា បានជាវាមកវិញដូច្នោះ ?

-ខ្ញុំបោះវានៅគំនរសំរាមឯណោះទេតើ ! គួរអោយឆ្ងល់ណាស់អាចង្រៃនេះវាម៉េចក៏ចូលទៅនៅក្នុងទ្បាំងទេវិញ ?

កំពុងតែពិចារណា ស្រាប់តែមានសម្លេងមនុស្សស្រែកហៅ នៅក្រៅរបងផ្ទះ

ពូជិម ! អីពូជិម ! មីងសៅ ! អីមីងសៅ !

ពូនិងមីង ឮសម្លេងមនុស្សហៅ ក៏ស្ទុះមីម្នាយកកញ្ចប់កាំភ្លើងទៅរកកន្លែងលាក់ ។ស្ពន់ពេកមិនដឹងលាក់ឯណាម្តងដាក់ក្នុងចង្ក្រានបាយ ម្តងយកពីចង្ក្រានមកដាក់លើហ៊ឹងក្បាលដំណេកមិនសុខមិនសាប់ យកពីរហ៊ឹងក្បាលដំណេក មកលាក់ក្នុងភ្នួយហើយយកខ្នើយដាក់សង្កត់ពីលើ ។

មីងស្ទុះចេញមកក្រៅផ្ទះ ឃើញបុរសម្នាក់ដែលគាត់ធ្លាប់ស្គាល់ នៅស្រុកជាមួយគ្នាដើរចូលមក ក្នុងរបងផ្ទះបែបរាងប្រញាប់បន្ទាន់ណាស់ ។

-នែពូ ! ប្រញាប់ទៅមន្ទីរពេទ្យព្រះសង្ឃភ្លាមទៅ ! កូនស្រីពូឯងដែលលក់បន្លែនៅផ្សារដើមគរនោះ ត្រូវឡានគៀរស៊ីក្លូរបួសដេកពេទ្យហើយ !

ពូជិមឈរភាំងស្ពន់និងដំណឹងគ្រោះថ្នាក់នេះ ។
មីងសៅស្ទុះទៅទាញក្រមាមកបង់ក រុញពូជិម ដែលកំពុងឈរធ្វើរូបចម្លាក់ អោយទៅយកស៊ីក្លូមកជាប្រញាប់ ។ មីងឡើងជិះស៊ីក្លូ ពូអ្នកធាក់ សំដៅទៅពេទ្យលោកសង្ឃ ។ ភ្លេចរឿងកាំភ្លើងទុកចោលនៅក្រោមខ្នើយនោះទៅ ។

មីង និងពូ បានជួបកូនស្រីគាត់ ដែលពេទ្យកំពុងរុំរបួសនៅក្នុងសាលសង្គ្រោះបន្ទាន់ ។

គាត់ទាំងពីរនាក់បានធូរស្រាលក្នុងចិត្តបន្តិច ដោយសារពេទ្យប្រាប់ថារបួសកូនស្រីគាត់មិនធ្ងន់ធ្ងរពេកទេ គ្រាន់តែភ្លាត់ឆ្អឹងប្រអប់ជើង និងរយះសាច់កំភួនជើងមួយជុំ អាចនិងព្យាបាលជាក្នុងរយៈពេល១ខែ ។

ពេលដែលពូជិមនិងមីងសៅ ស្ថិតនៅក្នុងមន្ទីរពេទ្យនាយសារ៉ាន់ក៏មកដល់ឃ្លាំងវិញដែរ ។ នាយបានរកម៉ូយទិញកាំភ្លើងបានហើយ សន្យាគ្នាថា និងប្រគល់កាំភ្លើងប្រគល់លុយ ដល់ដៃទៅវិញទៅមកនៅម៉ោង ៧យប់នេះ ។

នាយឆ្លៀតដើរទៅក្រោយឃ្លាំង ត្រង់គំនរឡាំង ដើម្បីត្រួតពិនិត្យមើលរបស់សំខាន់ដែលលាក់ទុកនៅទីនោះ ។

រំពេចនោះ នាយភ្ញាក់បើកភ្នែកធំៗ ព្រោះគំនរឡាំងត្រូវរបាត់របាយរលស់អស់មួយចំនួន បាត់ទាំងឡាំងដែលខ្លួនបានលាក់វត្ថុសំខាន់នោះថែមទៀត ។នាយនឹកឆ្ងល់ថានរណាគេមកយកឡាំងទាំងនេះទៅ ? នាយបកក្រោយ ស្ទុះរឹងទៅសួរពូឈុំដែលកំពុងកាន់បញ្ជីដើរតម្រង់ ទៅបើកទ្វារឃ្លាំង ។

_លោកមា!មានដឹងថាអ្នកណាមកយកសំបកឡាំងក្រោយឃ្លាំងទេ?

ពូឈុំងាកមកសម្លឹងមុខសារ៉ាន់បន្តិច ហើយតបថា ៖

_សំបកឡាំងនោះ អញអោយប្អូនជិមចាក់ស៊ីក្លូនៅក្រោយឃ្លាំងខ្លះហើយ !

_លោកមាអោយសំបកឡាំងគេម៉េចមិនប្រាប់ខ្ញុំអោយដឹងមុនផង ?

ពូឈុំដោះវ៉ែនតាចេញពីភ្នែក ចងចិញ្ចើមប្រែទឹកមុខមាំ ហើយនិយាយម៉ាត់ៗថា ៖

_ស្អីអាសារ៉ាន់ ! ឯងនិយាយយ៉ាងម៉េចហ្នឹង ? ឯងចៅហ្វាយអញ ពីកាលណា គ្រាន់តែអញអោយសំបកឡាំងគេ ចាំបាច់សួរឯងមុនដែរ ?



_មិនមែនដូច្នោះទេលោកមា ! ខ្ញុំចង់និយាយថាសំបកឡាំងនេះ ខ្ញុំត្រូវការសុំលោកមាខ្លះដែរ

_អញទើបអោយប្អូនជិម បួនដប់ឡាំងទេតើ ! សំបកឡាំងនៅសល់គរគោគ ឯងចង់យក មិនទៅយកខ្លះទៅ ! ប៉ុន្តែអញដូចជាឆ្ងល់ ថាឯងត្រូវការសំបកឡាំងយកទៅធ្វើអី ?.។

សំនួររបស់ពូឈុំ ធ្វើអោយនាយសារ៉ាន់ រាងអេះអុញបន្តិចទើបឆ្លើយថា ៖

_ខ្ញុំ.......ខ្ញុំបានរើសសំបកឡាំង ១ចំនួនល្អៗទុក ដោយគិតថាថ្ងៃអាទិត្យនេះខ្ញុំនិងដឹកយកទៅធ្វើរានលក់ដូរ អោយអាណោតក្មួយស្រី លោកមានៅឯកៀនស្វាយនោះណា៎ លោកមា ។

_មិនបាច់ទេ ! អញដឹងឬកឯងហើយ ! យកឈេសដឹកឡាំងទៅធ្វើ រានលក់ដូរអោយខ្មេត ម៉េចចង់ទាក់ទងក្មួយស្រីអញឬ ? ម៉ែឪវាស្អប់ឯងខ្លាំងណាស់ កុំទៅល្អជាង ! ។ ទៅ ! ទៅផ្លាស់ខោអាវមកជួយលើកអីវ៉ាន់ដាក់ឡាន ។

សារ៉ាន់ទាល់ច្រកដើរត្រឡប់មកកាន់រោងសំរាកវិញស្រាប់តែនឹកឃើញអ្វីម្យ៉ាងក៏ដើរគេចហួសទៅផ្ទះពូជិមនៅក្រោយឃ្លាំង...

គេអើតមើលពីក្រៅរបង ឃើញទ្វារផ្ទះពូជិមចាក់សោរពីក្រៅពុំ ឃើញមានមនុស្ស ។ នាយដើរក្រឡឹងទៅក្រោយផ្ទះ រកមើលសំបកឡាំង មិនប្រទះឃើញសោះក៏គិតថាឡាំងនោះប្រាកដជានៅក្នុងផ្ទះ ។ សារ៉ាន់ឃើញទ្វារផ្ទះបាយខាងក្រោយគ្រាន់តែខ្ទាស់ មិនចាក់សោរទេក៏លូកដៃតាមប្រឡោះជញ្ជាំងរហែក ដកជន្លួលចេញហើយបើកទ្វារចូលយ៉ាងស្រួល ។ គេឃើញឡាំងគរពាសពេញក្នុងផ្ទះ ទើបតែគាស់បាន ២-៣ ឡាំងប៉ុណ្ណោះ មានឡាំងមួយដែលគេចំណាំបានថា ជាឡាំងលាក់

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



រក្សាសិទ្ធិគ្រប់យ៉ាង

កាំភ្លើងនោះបានត្រូវ គាស់របើកហើយ ។ នាយរាវរកមើលក្នុងឡាំង នោះពុំឃើញកាំភ្លើង ក៏ស្ទុះស្ទាររកមើលគ្រប់ទីកន្លែងក្នុងផ្ទះ តែរកពុំឃើញទៀត ។ គេក៏ងើកកាយមើលឈើគ្រែផក ទើបប្រទះឃើញកាំភ្លើងដាក់ក្រោមភួយ ។ នាយសប្បាយចិត្តណាស់ លាក់ផ្សែងយ៉ាងប្រញាប់ យកកាំភ្លើងមកសៀតនៅចង្កេះខោ ហើយរភ្នែកទៅប្រទះឃើញកូនពូថៅដៃមួយ នៅក្បាលដំណេក ក៏យកពូថៅនោះ ដែលមានទំហំប្រហាក់ប្រហែលនិងកាំភ្លើងដែរ យកមករុំជំនួសកាំភ្លើងដាក់ក្នុងភួយដដែល យកខ្សែយសង្កត់ពីលើរក្សាសភាពដើម រួចម្ល៏ម្នាចាកចេញពីផ្ទះពូជិម ។

នាយសារ៉ាន់ចូលមកដល់រោងសំរាកវិញ ក៏ប្រទះភ្នែក និងនាងម៉ាចអ្នកដាំបាយកំពុងចិតបន្លែដាក់ស្លនៅក្បែរចង្ក្រានបាយ ។ សារ៉ាន់សម្លឹងនាងម៉ាចតែត្រូវម៉ាចសំឡក់វិញ ក៏ដើរហួសទៅដៃកបារីមកអុជជក់ ។នាយកេះដែកកែះអុជបារី តែដែកកេះអស់ហ្គាស់កេះមិនឆេះ ក៏ដើរទៅរើសអង្កត់អុសមួយពីក្នុងចង្ក្រានមកអុជបារី ។ ពេលងើបឡើងមិនបានជាគិត កាំភ្លើងដែលសៀតនៅចង្កេះខោ ក៏របូតធ្លាក់ក្តុកទៅដី នៅចំមុខនាងម៉ាចតែម្តង ។ នាងម៉ាចកំពុងចិតម្នាស់ស្លរម្ជូរ ឃើញកាំភ្លើងភ្ញាក់ជ្រុលដៃមុតកាំបិតចេញឈាមក្រហមឆ្អៅ ។ សារ៉ាន់ម្ល៏ម្នារើសកាំភ្លើងលាក់ទុកក្នុងអាវវិញជាបន្ទាន់ ។

នាងម៉ាចងើបឈរយ៉ាងរហ័ស ខ្ទប់ម្រាមដៃដែលមុតកាំបិតគិតក្នុងចិត្តថា ៖

"អាក្មេងនេះមានកាំភ្លើងផងតើ ! វាបានកាំភ្លើងពីណាមក ? វីវរហើយវាទាស់ជាមួយខ្ញុំពីម្សិលម៉ិញ ! វាយកកាំភ្លើងមកគម្រាមបាញ់ខ្ញុំទេដឹង ? មិនស្រួលទេខ្ញុំ មិនទុកចិត្តអាកូនក្មេងនេះទេ! រឿងនេះត្រូវរាយការណ៍ប្រាប់មេឃុំអោយដឹងទើប បាន "។ នាងម៉ាចគ្រាន់តែគិត តែមិនទាន់បានទៅរាយការណ៍ប្រាប់ពូឃុំទេ ។ ឯសារ៉ាន់នឹកបារម្ភយ៉ាងខ្លាំង មិនគួរធ្លាក់កាំភ្លើងមុខនាងម៉ាច អោយនាងម៉ាចឃើញសោះ ។





នាយដើរសំដៅឃ្លាំង ជួយជញ្ជូនអីវ៉ាន់កម្មករឯទៀតដាក់ឡាន ។ ភ្នែកនាយចេះតែលួចសម្លឹងមើលទៅនាងម៉ាច ក្រែងនាងម៉ាចទៅរាយការណ៍ប្រាប់អ្នកណា ពីរឿងគេមានកាំភ្លើង ។ អារម្មណ៍សាវ៉ាន់មិនស្រួល លើកប្រអប់ធំមួយដែលដាក់សំភារៈបន្ទប់ទឹករាងធ្ងន់បន្តិចចេញពីក្នុងឃ្លាំង ឯភ្នែកមិនសូវបានមើលផ្លូវ រវល់តែសម្លឹងមើលនាងម៉ាចដែលនៅឯឆ្ងាយឯណោះ ក៏ទៅជំពប់ជើង ទើសនិងពូឈុំដែលអង្គុយកត់ចំនួនសំភារៈ ដួលទាំងមនុស្សទាំងប្រអប់ សង្កត់លើពូឈុំ ។ ពូឈុំដួលផ្ងារក្រោយ ត្រូវមួយប្រអប់ចំក្បាលថែមទៀតរបូតវ៉ែនតាជ្រុះទៅដី សំណាងល្អមិនបែកកញ្ចក់ទេ ។





ពូឈុំក្តៅដូចភ្លើង ងើបឡើងយកខ្នងដៃបិចចង្កុលមុខសាវ៉ាន់ហើយវាយក្បាលសាវ៉ាន់ ១ប៉ុកស្តីអោយថា ៖

_អាឡប់ ! វាអាម៉េចឯងថ្ងៃហ្នឹង ! ភ្នែកឯងខ្វាក់ទេឬ ផ្លូវប៉ុនណាប៉ុនណឹមកដើរជាន់អញទាំងរស់ !

_អោយខ្ញុំសំទោសផងលោកមា !....នាយសាវ៉ាន់ស្ទុះងើបឡើង ដោយប្រុងប្រយ័ត្នខ្លាចធ្លាក់កាំភ្លើងពីចង្កេះទៀត ។

ពូឈុំសំឡក់សាវ៉ាន់មិនទាន់បាត់ក្តៅនៅឡើយ តែគាត់មាននិស្ស័យជាមនុស្សមិនបង្ករឿងក៏សុខចិត្តនៅស្ងៀមទៅ ។ នាយម៉េងស្ទូហ្វ័រឡាន រៀបអីវ៉ាន់លើឡាន



បណ្តើរសើចចុកពោះបណ្តើរ ។

សារ៉ាន់លើកប្រអប់ដើរតេះតះ ទៅហុចអោយនាយម៉េង ។ ទោះបីត្រូវជួលប៉ុណ្ណឹងហើយ ក៏ភ្នែកនាយមិនបានកាត់ផ្តាច់ពីនាងម៉ាចឡើយ ។ ចៃដន្យអី ស្រាប់តែឃើញនគរបាលពីរនាក់ឈរនិយាយជាមួយនាងម៉ាច ។ សារ៉ាន់ខំញីភ្នែកមើលនាងម៉ាចដែលកំពុងឈរនិយាយជាមួយនគរបាលនោះ ។ គេឃើញនាងម៉ាចចង្អុលមកចំរូបគេ ។ នគរបាលពីរនាក់នោះក៏ដើរសំដៅមក ។ វីវរហើយគិតយ៉ាងម៉េចអីចេះ ? ប្រហែលជានាងម៉ាចប្តឹងប៉ូលីសអោយចាប់គេទេដឹង ? ព្រោះគេមានតាំភ្លើង ? តើត្រូវរត់គេចខ្លួនឬយ៉ាងម៉េច ? ទេ ! ប្រថុចណាស់គេចមិនទាន់ទេ ។

នាយក៏ស្រវាឡើងលើឡាន ធ្វើជាជួយរៀបឡាំង និងប្រអប់អីវ៉ាន់ជាមួយនាយម៉េង ។ នាយម៉េងឃើញសារ៉ាន់ឡើងមកលើឡាន ក៏ដេញចុះទៅវិញ ៖






_អាខ្វាន់ ឯងនៅជួយជញ្ជូនគេខាងក្រោមទៅ ឡើងមកធ្វើអីទុកភារៈលើឡានអោយអញអ្នករៀប ។

_ទេ ! ខ្ញុំសុំជួយរៀបបងម៉េងឯងផង !

_មិនបាច់ទេ ! អីវ៉ាន់ប៉ុណ្ណឹងអញរៀបម្នាក់ឯងបានហើយ !អញអត់ត្រូវការឯងជួយទេ ! ចុះទៅក្រោមទៅ ! នាយសារ៉ាន់នៅឈរអេះអុញលើឡាន ។

ប៉ូលីសពីរនាក់នោះមកដល់ និយាយទៅកាន់ពូឈុំ

_ពូ ! នៅទីនេះមានសមាជិកកម្មករស្រី ប្រុសប៉ុន្មាននាក់ ? សូមប្រមូលគ្នាមកធ្វើស្ថិតិចុះបញ្ជី និងពិនិត្យអ្នកមានអាវុធជាតិផ្ទុះផង ! ។

ពូឈុំស្រែកប្រាប់កម្មករទាំងអស់ អោយមកជុំគ្នាកត់ឈ្មោះ អាយុស្រុកកំណើតធ្វើស្ថិតិ ។

កម្មករមកជួបជុំគ្នាអស់ ទាំងនាយម៉េងបើកឡានក៏ចុះពីឡានដែរ ។នៅសល់តែនាយសារ៉ាន់ម្នាក់ឯងនៅធ្វើច្រេមច្រំមិនព្រមចុះ ។

សារ៉ាន់បែកញើសថ្ងាស សស្រាក់ នឹកថាពេលនេះគិតយ៉ាងណាទៅ ? ខ្លួនមានអាវុធលាក់នៅចង្កេះ ។ ណាជានគរបាលផែកឃើញ មិនីវីវរនាយសម្លឹងឃើញប្រអប់

មួយរហែកល្មមស៊កកាំភ្លើងលាក់ បណ្តោះអាសន្នបានក៏ដកកាំភ្លើងពីចង្កេះយ៉ាងរហ័ស ស៊កចូលក្នុងឡាំងនោះភ្លាម ហើយលោតចុះពីលើឡាន ដើរធ្វើមិនដឹងទៅចូលរួមជាមួយ កម្មករឯទៀត ។ នាយម៉េងស្ងហ្វ័រឡានត្រូវចុះបញ្ជីមុនគេព្រោះប្រញាប់ដឹកអីវ៉ាន់ទៅ ដាក់អោយហាង។ចុះបញ្ជីរួចហើយនាយម៉េងក៏ឡើងឡានបើកចេញទៅ។ ឯនាយសារ៉ាន់កំពុងតែជាប់កត់ថ្ងៃខែចុះបញ្ជី ក្រឡេកឃើញនាយម៉េងបើកឡានចេញទៅអន្ទះសាចង់ឡើងឡានទៅតាមដែរ តែទៅមិនរួច ព្រោះនគរបាលកំពុងកត់ត្រាមិនទាន់ហើយ ។

ឡានាយម៉េងចេញទៅបាត់មួយសន្ទុះ   នាយសាវ៉ាន់រួចខ្លួនពីកិច្ចការកត់ត្រាស្ថិតិ  រត់ទៅហៅម៉ូតូឌុបជិះតាមឡាននាយម៉េង ។ ម៉ូតូឌុបបោះពួយតាមបញ្ជានាយសាវ៉ាន់  យ៉ាងលឿនតាមផ្លូវផ្សារដើមគរ  មកទាន់ឡាននាយម៉េង នៅជិតស្តុបទួលទំពូង ។ នាយសាវ៉ាន់បង្គាប់អោយម៉ូតូអែបជិតឡាន ហើយលើកដៃរាឃាត់ឡាននាយម៉េងអោយឈប់សិន ។នាយម៉េងឃើញសាវ៉ាន់រាដៃអោយឈប់ ក៏នឹកថាក្រែងមានការអីក៏អែបឡាននៅស្តាំហើយឈប់ ។ សាវ៉ាន់ស្ទុះឡើងលើឡាន ទាញយកប្រអប់ដែលលាក់កាំភ្លើងក្នុងនោះចុះពីលើឡាន ។ ម៉េងឃើញដូច្នោះស្ទុះ ទៅចាប់សាវ៉ាន់ជាប់រួចសួរថា ៖

-ឯងយកប្រអប់នេះទៅណា ?





-លោកមាអោយខ្ញុំមកយកប្រអប់នេះទៅវិញ !ព្រោះអត់បានកត់ចូលបញ្ជី.ពេលខ្ញុំជួលនោះគាត់ក៏ជួលដែរភ្លេចកត់ចូលបញ្ជី ។ ឥឡូវគាត់អោយខ្ញុំមកយកទៅវិញ ។

ទាំងទឹកមុខ  ទាំងកាយវិការ  ទាំងសំដីមិនធម្មតារបស់សាវ៉ាន់ធ្វើអោយនាយម៉េងកើតក្តីសង្ស័យយ៉ាងខ្លាំង ,ម៉េងក៏បន្លឺវាចាថា ៖

-ប្រអប់នេះ  យើងមិនអាចអោយឯងយកទៅបានទេ ! ទោះជា ប្រអប់នេះមិនបានកត់ចូលបញ្ជីក៏ដោយ ក៏ពេលយើងដាក់អីវ៉ាន់អោយហាងយើងក៏មានកំណត់ប្រគល់មួយទៀតដែរ  មិនអាចច្រឡំបានទេ ។ បើប្រអប់នេះនៅសល់គ្មានក្នុងបញ្ជី  យើងនិងយកទៅទុកឯឃ្លាំងវិញខ្លួនឯង  ! ប៉ុន្តែមិនអីទេ រឿងនេះយើងនិងតេទៅសួរបញ្ជាក់មាឃុំសិនក៏បាន ! ។ ម៉េងទាញទូរស័ព្ទដៃចេញពីរហោប៉ៅខោ  បំរុងតេទៅសួរពូឃុំតែត្រូវសាវ៉ាន់ឃាត់ថា ៖

-មិនបាច់តេទៅសួរគាត់ទេ ! គាត់ប្រើខ្ញុំមកផ្ទាល់ហើយ អោយតែបងម៉េងឯងប្រគល់ប្រអប់នេះមកខ្ញុំវាជាការស្រេចទៅហើយ ! ។

-ដាច់ខាតយើងមិនអោយឯងទេ ! ឯងកុំមកលេងល្បិចអីដាក់អញរ៉ុយ ! ។

ឮសំដីនាយម៉េងដាច់ណាត់ដូច្នោះ  សាវ៉ាន់ក្តៅស្លឹកត្រចៀកង៉ុង  អោបប្រអប់ជាប់បំរុងឡើងជិះម៉ូតូឌុបចេញទៅ  តែត្រូវនាយម៉េងចាប់អាវជាប់ ។ ការប្រតាយគ្នាទៅវិញទៅមក  ក៏ចាប់ផ្តើមធ្វើអោយនគរបាល   ដែលឈរយាមនៅកាច់ជ្រុងផ្លូវក្បែរនោះដើរសំដៅមក ។

សាវ៉ាន់ឃើញនគរបាលដើរមក  ក៏បោះប្រអប់នោះទៅលើឡានវិញហើយឡើងម៉ូតូឌុបជិះចេញទៅ ។ នាយម៉េងយកប្រអប់ទៅរៀបដាក់កន្លែងដដែលវិញ ។ នគរបាលមកអើតមើលឡានហើយសួរថា ៖

-មានរឿងអី ប្រទាយប្រទង់គ្នាអម្បាញ់មិញ ?

-បាទអត់មានរឿងអីទេបង ! អាពួកម៉ាកខ្ញុំម្នាក់នោះវាឡប់ វាលេងកំប្លែងជាមួយខ្ញុំបាទ !

-ឡានដឹកអីហ្នឹង ?

-បាទឡានឃ្លាំងដឹកសំភារៈសំណង់បាទ !

-អោយខ្ញុំសុំមើលវិក័យប័ត្រ និងមុខទំនិញ !

-បាទនេះលោក នាយម៉េងហុចវិក័យប័ត្រចេញពីឃ្លាំងអោយប៉ូលីស ។ ប៉ូលីសបើកបង្អើបមើលប្រអប់ពីរ បីនៅកន្ទុយឡាន ឃើញសំភារៈសំណង់មានកំប៉ុងថ្នាំពណ៌ធុងថ្នាំពណ៌ ។ល។ ក៏ហុចវិក័យប័ត្រអោយនាយម៉េងវិញ ហើយធ្វើសញ្ញាអោយចេញដំណើរទៅចុះ ។

ម៉េងបើកឡានបណ្តើរ គិតបណ្តើរថា ៖ "ហេតុអី បានជាអាសាវ៉ាន់វាចង់បានប្រអប់នេះតក្កហលម្ល៉េះ ? វាមានបញ្ហាអីទាក់ទងនិងប្រអប់នេះឬ ?តើប្រអប់នេះមានអាថ៌កំបាំងអ្វី ?"

ម៉េងបញ្ឈប់ឡានទៅក្បែរថ្នល់ ភ្នែករំពៃរកមើលសាវ៉ាន់ មិនឃើញមកតាមក្រោយទេ ក៏ឡើងទៅលើឡានទាញយកប្រអប់ដែល មានបញ្ហានោះមកឆែកមើលក៏ស្រាប់តែឃើញកាំភ្លើង ១ដើមនៅក្នុងនោះ ។

ម៉េងសើចងក់ក្បាលម្នាក់ឯង អីចឹងតើបានជាអាសាវ៉ាន់វាតាមទារយកប្រអប់នេះទៅវិញ ។ តាមពិតគ្មានមាឈ្មុំណាប្រើវាមកទេ វាបន្លំលាក់កាំភ្លើងក្នុងប្រអប់នេះដើម្បីគេចពីភ្នែកនគរបាល ។ ល្បិចឯងនៅរាក់ណាស់អាល្អិតសាវ៉ាន់អើយ កាំភ្លើងនេះធ្លាក់ដល់ដៃអញហើយ ចូរឯងកុំបីសង្ឃឹមថាយកទៅវិញបានអោយសោះ ។

ម៉េងស៊កកាំភ្លើងនៅចង្កេះខោ យកអាវគ្របពីលើ ហើយបើកឡានបន្តទៅទៀត ។ គេដឹងថា សាវ៉ាន់ប្រាកដជានៅចាំតេងហាង ដែលគេត្រូវយកសំភារៈទៅ



ប្រគល់អោយនោះមិនខាន ។ ដូច្នេះចាំបាច់គេត្រូវយកកាំភ្លើងនេះទៅលាក់ទុកកន្លែងណាមួយសិន ។ ម៉េងក៏បត់ឡាន ចូលទៅច្រកផ្លូវមួយ សំដៅទៅផ្ទះបងស្រីគេម្នាក់ជាភរិយាលោកថៅកែមហាសិរីភោគា ។ គេចតឡាននៅមុខភូមិគ្រឹះដ៏ ស្កុកស្គម្ភរបស់លោកថៅកែរួចឡើងទៅរកបងស្រីគេនៅជាន់ទី ១ ។ ពេលនោះអ្នកស្រីភោគាកំពុងចាត់ចែងអោយអ្នកបំរើរៀបចំម្ហូបអាហារទៅដាក់បិណ្ឌនៅវត្ត ក្រឡេកឃើញប្អូនប្រុសដើរចូលមកក៏សួរថា ៖

-ម៉េង ឯងមានការអីហ្នឹង ?

-បាទខ្ញុំមកលេងអ្នកបងហ្នឹងណា៎ បងប្រុសទៅសាំងហ្គាពួ មកវិញអង្កាល់អ្នកបង ?

-ប៉ាវ៉ា Fax មកប្រាប់ខ្ញុំថា មកវិញស្អែក !

-បងមី (ឈ្មោះដើមអ្នកស្រីភោគា) ខ្ញុំមានការបន្តិចចង់ពឹងបង ។

អ្នកស្រីភោគា សម្លឹងមុខប្អូនហើយសួរថា ៖

-ឯងមានការអីម៉េង ?

-នេះជាកាំភ្លើងរបស់ខ្ញុំ ខ្ញុំផ្ញើបងមីអោយទុកអោយខ្ញុំសិន ។ ចាំពីរបីថ្ងៃទៀតខ្ញុំសុំច្បាប់បានខ្ញុំមកយកវិញ ។

-ប៉ាវ៉ាគាត់មានកាំភ្លើងនេះ ១ដើមដែរទុកក្នុងបន្ទប់ឥឡូវឯងយក១ដើមមកផ្ញើទៀត ក្នុងផ្ទះបងមានកាំភ្លើងដល់ទៅពីរដើម មិនល្អទេដឹងម៉េង !

-មិនអីទេអ្នកបង ! ផ្ទះអ្នកបងគ្មានអ្នកណាគេមកឆែកឆេរអីទេ ខ្ញុំសុំផ្ញើតែ ៣ថ្ងៃទេខ្ញុំមកយកទៅវិញហើយ ។អ្នកស្រីភោគាយល់ដល់ប្អូនបង្កើតក៏ទទួលកាំភ្លើងដើរចូលទៅក្នុងបន្ទប់ បើកថតតុក្បាលដំណេកដាក់កាំភ្លើងទុកក្បែរកាំភ្លើងរបស់ប្តីគាត់ ។ គាត់ចេញពីបន្ទប់ដោយប្រញាប់ភ្លេចចាក់សោរទ្វារ ។

នាយម៉េង ងើភ្នែកមើលឆ្វេងស្តាំហើយ សួរលោកស្រីភោគាថា ៖

-អ្នកបង ដូចជាមិនឃើញក្មួយ ម៉ូដែល និងម៉ូដែន ?

-អូ ! កូនដែល និងកូនដែន វាជិះម៉ូតូទៅណាបាត់តាំងពីព្រឹកម្ល៉េះ ! ។

នាយម៉េងលាបងស្រី ចុះមកក្រោមវិញ ក៏ប្រទះនិងក្រុមយុវជនសង្ហារមួយក្រុម ជិះម៉ូតូចូលមកក្នុងរបងភូមិគ្រឹះ ។ ក្នុងចំណោមយុវជនទាំងនោះក៏មាន ម៉ូដែល និង ម៉ូដែនជាក្មួយរបស់គេដែរ ។

-អេ ! ពូម៉េងឈប់សិន !( យុវជនម៉ូដែនចុះពីលើម៉ូតូស៊ុយស៊្មីយតីវ៉ា ហើយដើរទៅអោបចង្កេះពូម៉េងរបស់គេ )។

-ម៉ូដែន ! ឯងទើបមកពីរណាហ្នឹង ? ឯងមានពួកម៉ាកអីច្រើនម្ល៉េះ ?

( ម៉េងសួរទៅក្មួយរបស់គេ )

-ខ្ញុំទើបមកពីច្រៀងការ៉ាអូខេណាំពូ ! ពួកម៉ាកច្រើនទើបសប្បាយ !

-ជិតដល់ពេលប្រលងហើយ ឯងពីរនាក់បងប្អូនមិនខំរៀនទេឬ ?

ម៉េងឆ្ងៀតដាស់តឿនក្មួយទាំងទឹកមុខញញឹម ។តែក្មួយរបស់គេបែជាសើចកក្អឹក ហើយពោលបែបងាយវិញថា ៖

-ព្រោះតែចង់ប្រលងជាប់នេះហើយ បានជាខ្ញុំត្រូវដើរលេងអោយច្រើនអោយវាថ្លាខួរក្បាលរៀនឆាប់ចូលណាំពូ !

ម៉េងឮក្មួយពោលដូច្នោះ ហួសចិត្តឥតវាចានិងថ្លែង ក៏បែសម្លឹងទៅក្មួយម៉ូដែលម្តងវិញ គេបំរុងនិងហៅក្មួយ ប៉ុន្តែនាយម៉ូដែលជាប់និយាយទូរស័ព្ទដៃគ្រាន់តែសើចតួរសមមក៏មារបស់គេពុំអាចផ្តាច់ការសន្ទនាទូរស័ព្ទរបស់គេបានឡើយ " យើងជួបគ្នានៅឯណា ? វត្តគៀនស្វាយ ? ម៉ោងប៉ុន្មាន ? អូខេ ! "

នាយម៉េងដោយមានធុរៈប្រញាប់ទៅដាក់អីវ៉ាន់ ក៏ដើរសំដៅទៅរថយន្តហើយ



បើកចេញទៅ ។

ម៉ូដែលនិយាយទូរស័ព្ទចប់ ក៏ស្រែកប្រាប់ទៅក្រុមមិត្តភ័ក្តរបស់គេ បួនប្រាំនាក់ដែលកំពុងហក់លោតទាត់ធាក់គ្នារញីរញៃពេញសួនច្បារថា ៖

-នែ ក្រុមខ្មោចឆៅទាំងឡាយ ! ឯងនៅចាំយើងខាងក្រោមនេះ ហើយយើងឡើងទៅរកម៉ាក់យើងឮទេ ? ពោលរួចហើយ ម៉ូដែល និង ម៉ូដែនរត់ឡើងជណ្តើរទៅជាន់ទី១ ។ ម៉ូដែល និង ម៉ូដែនធំក្លិនអាហារ ឈ្ងុយឆ្ងាញ់ពេញបន្ទប់ក៏លាន់មាត់ថា ៖

-ថ្ងៃនេះម៉ាក់ធ្វើម្ហូបអីឈ្ងុយម្ល៉េះ?( ម៉ូដែលពោលហើយសម្លឹងទៅតុបាយឃើញម្តាយរបស់គេកំពុងជួសម្ហូបដាក់ស្រាក់ បំរុងទៅវត្ត អ្នកកំលោះស្ទុះស្ទៀតទៅបើកគំរបចានស្រាក់ឃើញសម្លរការីសាច់ជ្រូកឡើងក្រហម តួរស្រក់ទឹកមាត់ចង់បរិភោគក៏យកដៃចាប់សាច់មួយដុំក្នុងចានពមយ៉ាងរហ័ស អ្នកស្រីភោគាឃើញកូនធ្វើដូច្នោះស្រែកអោយកូនថា ៖

-ម៉ូដែលម៉េចកូនធ្វើដូច្នេះ ! ម្ហូបក្នុងចានស្រាក់នេះម៉ាក់សំរាំងយកទៅវត្តណាំកូន ! សំរាប់ប្រគេនលោក បង្សុកូលឧទ្ទិសកុសល ជូនដល់លោក យាយ លោកតាព្រមទាំងញាតិយើង ដែលបានចែកឋានទៅបរលោក បើកូនហូបម្ហូបទាំងនេះអត់របៀបដូច្នេះកូននិង"បាប"មិនខាន !

-បាប ? បាបស្អីទៅម៉ាក់ ? មនុស្សស្លាប់បាត់អស់ទៅហើយ មិនដែលចេះហូបម្ហូបឆ្ងាញ់ៗអីចឹងទេ ! ខ្ញុំ ! នៅរស់ទើបចេះហូប !

-កូនព្រើល ! និយាយអី អីចឹង ! ម្ហូបសំរាប់ឯង ម៉ាក់បានរៀបចំទុកដាក់ក្នុងទូចានឯណោះ ម៉េចមិនទៅយកហូប ។រួចឯងពីរនាក់ទើបមកពីរណា ?ក៏ត្រហេបត្រហបម្ល៉េះ ? ចុះឯណាខ្សែកកូនដែន ? ឯណាចិញ្ចៀនកូនដែល ? អ្នកស្រីភោគាសួរកូនទាំង

ពីរពេលក្រឡេកទៅ ឃើញតែកូនដែលចាត់ចិញ្ចៀន និង កូនដែនចាត់ខ្សែក ។

ក្មេងទាំងពីរធ្វើមុខជូរ សម្លឹងមុខគ្នាទៅវិញទៅមក ទើបឃុំវជនម៉ូដែលជាបងឆ្លើយមុនថា ៖

-ម៉ាក់ចិញ្ចៀនខ្ញុំអោយពួកម៉ាកខ្ញុំខ្ចីបាត់ហើយម៉ាក់....

-ស្អី ? ចិញ្ចៀនថ្លៃជិតពីរពាន់ដុល្លា អោយពួកម៉ាកខ្ចី ?របស់ថ្លៃយ៉ាងនេះកូនអោយគេខ្ចីអីងាយៗម្ល៉េះ ?

-បាទម៉ាក់ អាពួកម៉ាកខ្ញុំវាជិះម៉ូតូបុកគេ អត់លុយសងគេខ្ញុំអាណិតវាអោយចិញ្ចៀនវាខ្ចីលក់ យកលុយសងគេទៅម៉ាក់ ។

-អូយ អញខ្យល់គរស្លាប់ឥឡូវហើយកាដែល ! ចុះកាដែនម៉េចដែរបានជាបាត់ខ្សែក ? ។

-បាទម៉ាក់ ខ្សែកខ្ញុំអត់អោយពួកម៉ាកខ្ចីដូចបងដែលទេ ខ្ញុំយកទៅលក់ខ្លួនឯងបានបួនរយដុល្លា ហើយលុយនោះខ្ញុំអោយពួកម៉ាកខ្ញុំ ជូរម៉ូតូអាស៊ីរីថ្មីអស់ ២០០ដុល្លា នៅសល់ ២០០ដុល្លាខ្ញុំចាយជាមួយបងដែល អស់ទៅណាំម៉ាក់ ។

-ណ្ហើយ ! ឈប់និយាយទៅអញវិលមុខណាស់ ម៉្ងៃៗលីតែពួកម៉ាកៗ បង្ហិនបង្ហោចតែលុយកាក់ផ្ទះ ចិត្តល្អណាស់ជញ្ជូនរបស់ពីផ្ទះយកទៅអោយពួកម៉ាក ។ ឯងទាំងពីរនាក់នេះធំៗ ហើយណាំកូនល្មមចេះគិតខុស ត្រូវអាក្រក់ល្អហើយ ។ម៉ាក់ប្រដៅកូនរាល់ថ្ងៃតែកូនមិនស្ដាប់ម៉ាក់សោះ ។ឯងទាំងពីរនាក់រ៉ក់ដើរលេងភ្លេចរៀនភ្លេចសូត្រអស់ហើយ ម៉ាក់ពិបាកចិត្តណាស់ឃើញឯងប្រឡងធ្លាក់រាល់តែឆ្នាំ។ហើយឆ្នាំនេះត្រូវប្រលងម្ដងទៀតមិនឃើញប្រឹងរៀនសោះ ឃើញតែដើរលេងបាត់ៗពីផ្ទះ ។

វាចាប្រៀនប្រដៅដូចចាក់ទឹកលើក្បាលទា នេះបានត្រឹមតែធ្វើអោយ ក្មេងទាំង



ពីរឈរឈ្ងាកមុខរបៀបធុញថប់ប៉ុណ្ណោះ ។

ចប់ប្រយោគម្ដាយកាលណា ពួកគេសំដែងអាការរឡើរឡក់អោបដៃអោបជើងម្ដាយ ។ កញ្ជោះម៉ូដែល អង្វរម្ដាយថា ៖



-ម៉ាក់ហរ៉ា ! ម៉ាក់ !

-ស្អី ? មានការអីទៀតហើយ កាដែល ?

-ម៉ាក់អោយខ្ញុំសុំលុយម្នាក់ ២០០ដុល្លា មកម៉ាក់ !

-យកលុយទៅធ្វើអីច្រើនម្ល៉េះកូន ?

-មានច្រើនអីម៉ាក់ ២រយដុល្លាហ្នឹង ? បើថ្ងៃមុនតាចាញ់កាស៊ីណូអស់ ៥ម៉ឺនដុល្លាឯណោះម៉ាក់អត់ថាអីតាផង ។

-កុំយករឿងតាឯងមកនិយាយ!ម៉ាក់សួរថាកូនឯងទាំងពីរនាក់ត្រូវការលុយម្នាក់

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

២០០ដុល្លា យកទៅធ្វើស្អី ?

-ខ្ញុំយកទៅទិញកាដូបុណ្យខួបកំណើតពួកម៉ាកណាំ ម៉ាក់ !

-ហ៊ឺយកូននេះចំហើយវ៉ឺយ ទោះជាចេះបោះពុម្ពលុយក៏ជាឯង រកអោយឯងពីរនាក់ចាយមិនទាន់ដែរ...។

នាយម៉ូដែលកំពុងអង្វរសុំលុយម្តាយ ចំណែកម៉ូដែនជាប្អូនមើលទៅឃើញទ្វារបន្ទប់របស់ម៉ាក់ ប៉ាគេចំហបន្តិចភ្លេចចាក់សោរក៏ធ្វើសញ្ញាភ្នែកអោយម៉ូដែល នាំម្តាយគេនិយាយបន្តទៅទៀត ។ ឯរូបគេដកឃ្លា លបៗដើរសំដៅទ្វារបន្ទប់ ។ ពេលនោះមីងចាន់អ្នកបំរើ ឃើញម៉ូដែនបើកទ្វារបន្ទប់លោកស្រីដូច្នោះ ក៏បើកភ្នែកធំៗសម្លឹងមក ។ ម៉ូដែនធ្វើសញ្ញាអោយមីងចាន់ នៅស្ងៀមកុំមាត់អោយសោះ ។ នាយស្ទាវបើកទ្វារចូលក្នុងបន្ទប់ ដើរសំដៅទៅបើកថតតុក្បាលដំណេករកមើលលុយកាក់ ឬមាសប្រាក់របស់ប៉ាម៉ាក់គេ ។ ពេលនោះ គេបានប្រទះឃើញកាំភ្លើងពីរដើមនៅក្នុងថតតុនោះ ។ គ្រាន់តែឃើញកាំភ្លើងភ្លាម នាយលាន់មាត់ថា" អៃយ៉ាហេងមែន ! អញកំពុងតែត្រូវការអាហ្នឹងផង ! ប៉ាបានកាំភ្លើងពីណាមកដល់ទៅពីរដើម ! ខ្ញុំគួរតែយក១ដើមទុក ១ដើមអោយប៉ាប្រើចុះ "។គិតហើយម៉ូដែនយកកាំភ្លើងដែលនាយម៉េងផ្ញើទុកនោះស៊ៀតចង្កេះខោ ហើយរើកកាយថតតុនោះ ឃើញប្រអប់មួយមានចិញ្ចៀន ត្បូងទទឹមត្បូងពេជ្រ ១កញ្ចប់ទៀត ។ ម៉ែនសប្បាយចិត្តណាស់ ក៏យកចិញ្ចៀនពីរបីវង់ដែលភ្លឺផ្លេកៗដោយត្បូងពេជ្រដាក់ក្នុងហោប៉ៅខោហើយ ប្រញាប់ចេញមកក្រៅវិញ ។

បានប្រាក់ ២រយដុល្លាម្នាក់ហើយ ។ យុវជនទាំងពីរប្រញាប់រត់ចុះជណ្តើរមកក្រោមប្រមូលគ្នីគ្នាឡើងម៉ូតូប្រែនចេញទៅបាត់ស្រមោល ។

និយាយពីរនាយម៉េង ដែលបើកឡានចេញពីផ្ទះបងស្រីគេមក ក៏ជួបសារ៉ាន់នៅមុខហាងលក់គ្រឿងសំណង់ ដែលគេត្រូវដាក់អីវ៉ាន់ចុះនោះ ។ ម៉េងធ្វើមិនឃើញ



សារ៉ាន់ ឯសារ៉ាន់ឈរអន្ទះសាចាំនាយម៉េងយូរហើយ ។ នាយម៉េងជីអីវ៉ាន់ចេញពីឡានជញ្ជូនចូលហាងជាមួយកម្មកររបស់ហាងនោះ ធ្វើដូចជាគ្មានបញ្ហាអីកើតឡើងទេ ។ សារ៉ាន់ឈរអើតអើមក្បែរឡាន សម្លឹងមើលឡាំងដែលជញ្ជូនចេញពីឡាន ។ ឡាំងចុងក្រោយបំផុតគឺឡាំងរហែកនោះ.នាយម៉េងធ្វើជាឈរកាន់ឡាំងសម្លឹងមើលនាយសារ៉ាន់ ឯសារ៉ាន់ស្ទុះមកបំរុងយកឡាំងនោះ តែត្រូវនាយម៉េងឃាត់ថា ៖

-ឈប់សិន ! អាសារ៉ាន់ ! ឯងចង់បានឡាំងនេះយកទៅវិញឬ ? ឬឯងចង់បានអីវ៉ាន់ក្នុងឡាំង ? នាយសារ៉ាន់ អិះក្បាលហើយសើចនិយាយថា ៖

-ខ្ញុំចង់បានទាំងឡាំងទាំងរបស់យកទៅវិញ !នេះជាបញ្ហាលោកមាឈុំទេតើ!

-កុំមកប្រូអញ ! អាមេប្រូ !បើថាចង់បានណាស់ហ៎ក !យកទៅឡាំងនេះអញប្រគល់អោយឯងហើយ !តែត្រូវដាក់ឡានយកទៅទុកឃ្លាំងវិញជាមួយអញឥឡូវ!ម៉េងហុចឡាំងក្រដាស់រហែកនោះទៅសារ៉ាន់ ហើយនាយដើរទៅយកវិក័យប័ត្រពីម្ចាស់ហាងស៊ីញ៉េចុះសៀវភៅកំណត់របស់ហាងសព្វគ្រប់ ក៏ដើរមកមើលនាយសារ៉ាន់វិញ ។ ឯសារ៉ាន់ រើកកាយក្នុងប្រអប់ពុំឃើញកាំភ្លើងរបស់គេ នឹកឆ្ងល់ខ្លាំងណាស់គេគិតថាគេពុំបានច្រឡំប្រអប់ទេពិតជាប្រអប់នេះហើយ ហេតុអីបានជាមិនឃើញកាំភ្លើងនោះ?

-អាសារ៉ាន់ឯងរើរកអីហ្នឹង ?ម៉េងឈរជក់បារីសើចពេញជាយអោយសារ៉ាន់ ។ សារ៉ាន់អង្គុយធ្វើមុខជូរ មើលមកម៉េង ហើយពោលអង្វរម៉េងថា ៖

-បងម៉េង ! អោយរបស់នោះខ្ញុំវិញមក ! ខ្ញុំសូមអង្វរ !

-របស់ស្អី ? ក្រែងឯងចង់បានឡាំងនេះឬ ឥឡូវអញអោយឯងហើយនៅមានរបស់ស្អីទៀត ?

-អាណិតកុំលេងសើចអីបងម៉េង ! អោយរបស់នោះមកខ្ញុំវិញមក ! ខ្ញុំយកវាទៅលក់យកលុយចាយ ! ។ ម៉េងនឹកអាណិតសារ៉ាន់ដែរតែមកនឹកឆ្ងល់ថាតើសារ៉ាន់បានកាំ

ភ្លើងនោះពីណាមក ? គេក៏សួរបញ្ជាក់សាវ៉ាន់ថា ៖

-ឯងប្រាប់អញអោយត្រង់មក ឯងបានកាំភ្លើងនោះមកពីណា ?

-ខ្ញុំរើសវាបានក្រោយឃ្លាំងពីយប់មិញ !

-ឯងនិយាយពិតឬ ?

-បាទ ! ខ្ញុំអត់កុហក់បងទេ ! ខ្ញុំទៅបត់ជើងក្រោយឃ្លាំង ស្រាប់តែមានគេបោះវាមកប៉ះជញ្ជាំងបង្កន់ខ្ញុំ ខ្ញុំខំរកមើលមនុស្សអ្នកបោះដែរតែ មិនឃើញខ្ញុំក៏រើសកាំភ្លើងនេះទុកលក់យកលុយចាយទៅ !

-ឯងរើសបានកាំភ្លើង ហេតុអីបានជាមិនយកទៅប្ដឹងប៉ូលីស បែរជាទុកលក់ទៅវិញ ! ឯងដឹងទេ ! កាំភ្លើងមានគ្រោះថ្នាក់ណាស់អ្នកមិនធ្លាប់កាន់មិនធ្លាប់ប្រើកុំចង់លេងជាមួយវាអោយសោះ ព្រោះវាជាឃាតករគ្មានវិញ្ញាណ ជនណាក៏អាចកេះកៃរបស់វាបានដែរ បើវានៅក្នុងដៃមនុស្សខ្វះសីលធម៌ វានិងបង្កវិនាសកម្មគ្រប់បែបយ៉ាង ។កាំភ្លើងជាបីសាចសម្លាប់គ្មានរើសមុខ បុណ្យសក្ដិកិត្តិយសអីទេសូម្បីម្ចាស់វាដែលកំពុងកាន់វានៅដៃ ក៏វាអាចសម្លាប់បានដែរ ។ ដូច្នោះហើយបានជាគេប្រកាសអំពាវនាវប្រមូលកាំភ្លើងយកទៅដាក់ឃ្លាំងរដ្ឋ គេថែមទាំងបង្កើតច្បាប់កាន់កាប់កាំភ្លើងផងបើជនណា មានអាវុធហើយគ្មានច្បាប់ត្រូវទទួលទោសឯងស្ដាប់វិទ្យុរាល់ថ្ងៃមិនឮទេឬ ?។

-ចឺក៏មិនឮ ចឺក៏មិនដឹងរឿងគេប្រកាសតាមវិទ្យុតាមទូរទស្សន៍ប្រមូលអាវុធជាតិផ្ទុះនោះ តែដោយសារខ្ញុំខ្វះលុយចាយ បានជាខ្ញុំលាក់វាទុកសំរាប់លក់ ខ្ញុំគ្មានគំនិតយកវាទៅប្រើអីផ្សេងទេ ។

-ឥឡូវយើងមិនបាច់និយាយគ្នាវែងឆ្ងាយទៀតទេ( ម៉េងអារកាត់ឡើង ) ខ្ញុំក៏ជាប់ពាក់ព័ន្ធរឿងកាំភ្លើង ១ដើមនេះដែរហើយ ។ខ្ញុំបានយកកាំភ្លើងពីក្នុងឡាំងនេះទៅ



ផ្ញើទុកនៅផ្ទះបងស្រីខ្ញុំឯណោះ ព្រោះខ្ញុំខ្លាចថៃវន្សមានប៉ូលីស ឬជនណាម្នាក់ផែកឃើញនាំមានរឿងរ៉ាវវែងឆ្ងាយ ។ រឿងកាំភ្លើងពុំមែនជារឿងល្អទេវាជារបស់ចង្រៃគួរខ្លាចណាស់ ។ ចាត់ទុកថាជាថ្ងៃស៊ិយរបស់យើងពីរនាក់ទៅចុះ ដែលមកជួបរឿងអពមង្គលដូច្នេះ ។ តោះសាវ៉ាន់ឡើងឡានមក ! ទៅយកកាំភ្លើងជាមួយគ្នា ។

អ្នកទាំងពីរធ្វើដំណើរប្រញាប់ប្រញាល់ សំដៅទៅផ្ទះអ្នកស្រីភោគាក៏ជួនគ្នានិងពេលអ្នកស្រី ត្រឡប់ពីរដាក់បិណ្ឌនៅវត្តវិញដែរ ។

-មានការអីទៀតហើយម៉េង ? អ្នកស្រីភោគាសួរទៅម៉េង

-បាទអ្នកបង ! ខ្ញុំមកសុំកាំភ្លើងដែលខ្ញុំផ្ញើទុកនិងអ្នកបងពីព្រឹកនោះវិញ !។

-អើ ! ចាំបងឡើងទៅយកអោយ ! ចាំមួយភ្លែត ! ។

អ្នកស្រីភោគាឡើងទៅជាន់ទី១ ចាក់សោបន្ទប់ហើយសំដៅទៅបើកថតតុយកកាំភ្លើងតែអ្នកស្រីស្រឡាំងកាំង ព្រោះបាត់កាំភ្លើងម៉េងពីថតតុ ឃើញតែកាំភ្លើងរបស់ប្ដីគាត់ ។ ចំនែកប្រអប់ដាក់គ្រឿងមាសពេជ្រ របស់គាត់ក៏របើករាយប៉ាយបាត់ទាំងគ្រឿងចិញ្ចៀនពេជ្រពីរ បីវង់ទៀតប៉ាន់តំលៃនៃការបាត់បង់នេះមិនតិចជាងពីរម៉ឺនដុល្លា! អ្នកស្រីឈរភាំង វង្វេងស្មារតីចង់ខ្យល់ចាប់ ។

-មីងចាន់ ! អីមីងចាន់ ! អ្នកស្រីស្រែកហៅអ្នកបំរើ

-ចាំ អ្នកស្រី ! មីងចាន់រត់មក ។

-មីងមានឃើញអ្នកណាចូលបន្ទប់ខ្ញុំទេ ?

-ចាំ...មីងចាន់រកនឹកបន្តិចទើបឆ្លើយថា ៖

ចាំអត់ទេ !...ចាំមាន !ខ្ញុំឃើញអ្នកប្រុសម៉ូដែនចូល !

-ចូលពីអង្កាល់ ?

-ចាំចូល ពេលអ្នកប្រុសម៉ូដែល កំពុងសុំលុយអ្នកស្រីនៅផ្ទះបាយ !។

គ្រាន់តែឮថាកូនម៉ូដែនចូលបន្ទប់ អ្នកស្រីអស់សង្ឃឹមហើយ ! ពិតជាវាពិតជាម៉ូដែនយកកាំភ្លើងនោះហើយ ! កូនជាទីស្រឡាញ់តែប្រយោជន៍មិនបាន វាពិតជាអោយទុក្ខលំបាកធ្ងន់ធ្ងរដល់ម៉ែឪមែន ! រឿងបាត់មាសពេជ្រតំលៃប៉ុណ្ណោះអ្នកស្រីមិនស្តាយប៉ុន្មានទេតែមកភ័យព្រួយរឿងកាំភ្លើង ! អាកូនឈាមរាវនេះវាយកកាំភ្លើងទៅណា ? វិវរហើយ ! តិចណាវាយកទៅបាញ់គេ ឬវាយកទៅប្លន់ទៅសំឡុតគំរាមគេឬ ក៏ត្រូវគេយកកាំភ្លើងនោះ បាញ់វាវិញ ! ឬក៏វាវពីសលេងកាំភ្លើងនោះ ដណ្តើមគ្នាពីរនាក់បងប្អូន វារាលកៃត្រូវខ្លួនប្រាណវាឬក៏ត្រូវគេចាប់វាបាន ព្រោះវាមានកាន់កាំភ្លើងពុទ្ធោអើយ ! កូនដែន កូននៅទីណា ?

អ្នកស្រីចង់ឡប់សតិ រត់តេះតះចុះជណ្តើរមកក្រោមវិញ ក៏ច្រឡំជើងជាន់លើស្បែកជើងរបស់អ្នកស្រីដែល ដោះទុកមាត់ជណ្តើរពេលអ្នកស្រីត្រឡប់ពីវត្តក៏ក្រឡាប់ជើងបណ្តាលអោយរាងកាយអ្នកស្រីដែលធាត់ទ្រលុកនោះដួលអុកឡូទទៅមាត់ជណ្តើរបាត់មាត់បាត់ក ។ ម៉េងស្ទុះមកជួយលើកបងស្រី ឯមីងចាន់ជួយរិតទ្រូង ព្រោះអ្នកស្រីមានជម្ងឺខ្សោយបេះដូង និងលើសឈាមផង ពេលនេះបើគ្មានអ្នកជួយសង្គ្រោះទេគ្រោះថ្នាក់ធ្ងន់ធ្ងរអាចនិងកើតឡើងបាន ។

បន្តិចមកអ្នកស្រីដឹងខ្លួនមានស្មារតីនិងន ក៏និយាយប្រាប់ម៉េងអោយតាមរកក្មួយជាប្រញាប់ ៖

-ម៉េង ! តាមរកវាទាំងពីរនាក់អោយបងអោយឆាប់បន្តិច !វាបានយកកាំភ្លើងដែលម៉េងឯងផ្ញើទុកនិងបងទៅបាត់ហើយ !

-អ្នកបងមានដឹងថាវាមានទម្លាប់ទៅទីណាទេ ? ម៉េងសួរបញ្ជាក់អ្នកស្រី

-ទេបងមិនដឹងទេ !ប្រហែលជាវាទៅផ្ទះមិត្តភក្តិវា !វាអត់មានទូរស័ព្ទមកប្រាប់បងសោះ ! ឱប្រហែលជាវាទៅចំការបងឯគៀនស្វាយក៏មិនដឹង ។



ម៉េងនឹកស្តាយកំហុសរបស់ខ្លួនក៏ពោលថា ៖ខុសមកពីខ្ញុំទេ !បើខ្ញុំមិនយកកាំភ្លើងនេះមកផ្ញើអ្នកបងក៏អ្នកបងមិនលំបាកដល់ម្លឹងដែរ ! ពេលនោះម៉េងស្រាប់តែនឹកឃើញអ្វីម្យ៉ាង :

-ព្រឹកមិញខ្ញុំឮក្មួយដែល ទូរស័ព្ទប្រាប់ពួកម៉ាកវា ថាវាណាត់ជួបគ្នាម្តុំវត្តគៀនស្វាយប្រហែលជានៅទីនោះហើយ ខ្ញុំសុំលាអ្នកបងទៅតាមវាឥឡូវនេះ ។

-ឯងគួរទូរស័ព្ទរកវាវិញល្អជាង ! ព្រោះវាអាចនៅទីកន្លែងផ្សេង (អ្នកស្រីអោយយោបល់ម៉េង)

ម៉េងទាញទូរស័ព្ទដៃមកចុចលេខទាក់ទងជាមួយក្មួយរបស់គេ ប៉ុន្តែទូរស័ព្ទត្រូវកាត់ផ្តាច់ពុំអាចទាក់ទងបាន ជំរើសមានតែមួយគឺ ម៉េងនិង សាវ៉ាន់ត្រូវរួសរាន់ឡើងឡានចេញដំណើរទៅគៀនស្វាយ ។

-ឃើញទេសាវ៉ាន់ (ម៉េងបើកឡានបណ្តើរនិយាយបណ្តើរ) រឿងកាំភ្លើងវាមិនធម្មតាទេ ឥឡូវវាធ្លាក់ដល់ដៃក្មួយខ្ញុំហើយ ! បើយើងរកកាំភ្លើងនិងមនុស្សមិនឃើញព្រឹកនេះទេរឿងរ៉ាវមិនដឹងយ៉ាងណាទេ !មានកាំភ្លើងគឺមានមច្ចុរាជម្នាក់នៅជាមួយ ។ ក្មេងឈាមរាវដូចម៉ូដែល ម៉ូដែនមានកាំភ្លើងនៅដៃវា មិនដឹងជាក្លាហានហក់ហោតប៉ុនណាទេ ។ ក្មេងៗឥឡូវចូលចិត្តមើលវីដេអូបាញ់កាប់ចាក់ អាសអាភាសសម្លាប់គ្នាឥតអាណិតអាសូរ រូបភាពទាំងនេះ វាថតជាប់ក្នុងអារម្មណ៍របស់វា , វាងាយនិងអនុវត្តតាមគំរូនោះ ។ គិតទៅគួរអោយស្តាយពេកណាស់ខ្ញុំនិងសាវ៉ាន់ឯងមិនគួរនាំទុក្ខលំបាកដល់បងស្រីខ្ញុំសោះ !

-ខុសមកពីខ្ញុំទេ !ដែលជាអ្នករើសបានកាំភ្លើងចង្រៃនោះ(សាវ៉ាន់ ឧទានឡើង) បើរកវាឃើញម្តងនេះខ្ញុំនិងកំទេចវាចោលអោយខ្ទេច ដូចអំបែងកែវ ! (សាវ៉ាន់ពោលទាំងឈឺចាប់ គេមិននឹកស្មានថាកាំភ្លើងនេះវាកើតទៅជារឿងរ៉ាវអាក្រក់ម្ល៉េះ )។

តាមពិតសារ៉ាន់ជាយុវជនម្នាក់ ធ្លាប់រៀនសូត្រនៅសាលាចំណេះទូទៅដល់ថ្នាក់ទី ១២ដែរតែគេបានប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទី២ គេក៏បញ្ចប់ការសិក្សាត្រឹមនោះ ។ នាយកំព្រាឪពុក សព្វថ្ងៃរស់នៅជាមួយម្តាយ ដែលមានទីលំនៅជិតវត្តគៀនស្វាយ ។ សារ៉ាន់បានត្រូវពូឈុំដែលជាញាតិមិត្តនៅស្រុកជាមួយគ្នា ហៅមកធ្វើជាឆ្មាំឃ្លាំងក្រុមហ៊ុនធំមួយ ។

ជាយូរមកហើយ នាយបានទាក់ទងយ៉ាងជិតស្និទ្ធជាមួយនាងសុណេត ជាក្មួយបង្កើតរបស់ពូឈុំ ត្រូវជាកូនក្រមុំចឹកឡោយាយឡេងដែលមានមុខរបរលក់ចាប់ហួយនៅក្បែរផ្ទះនាយឯភូមិគៀនស្វាយនោះ ។

ចឹកឡោយាយឡេង មិនសូវពេញចិត្តនិងសារ៉ាន់ទេព្រោះកម្លោះនេះគ្មានមុខការធ្វើច្បាស់លាស់ ។ ឯនាងសុណេត នាងបានដឹងច្បាស់ណាស់ទៅហើយថាសារ៉ាន់មានបំណងទាក់ទងនាងជាគូរអនាគតនាង ក៏មិនស្អប់ខ្ពើមសារ៉ាន់ដែរ ។ ព្រោះនាងស្គាល់សារ៉ាន់តាំងពីនៅតូចគ្រួចឆ្មារដូចគ្នា ។ តែនាងពុំទាន់បានបញ្ចេញអាកប្បកិរិយាណាមួយអោយសារ៉ាន់បានដឹងពីទឹកចិត្តនាងនៅឡើយ ។ ឯសារ៉ាន់ក៏បានយកចិត្តទុកដាក់និងនាងខ្លាំងណាស់ ហើយមើលការខុសត្រូវនាងដូចបងប្រុសនាងអីចឹង ។



## វគ្គទី ២ បុប្ផាគៀនស្វាយ



ម៉ោង ១១ព្រឹក ថ្ងៃជិតត្រង់ហើយ ព្រះអាទិត្យពុំបានចែងចាំងការស្ទើកំដៅផែនដីស្រុកគៀនស្វាយទេព្រោះមេឃទូរទឹម ភ្លៀងរលឹមសស្រិចតាំងពីព្រលឹមមក ។ អាកាសធាតុត្រជាក់ សែនមនោរម្យសមនិងថ្ងៃបុណ្យ ដាក់បិណ្ឌដែលពុទ្ធសាសនិកជនខ្មែរទាំងប្រុស ស្រីក្មេងចាស់ចាត់ទុកជាថ្ងៃបុណ្យប្រពៃណីពិសេសបំផុតប្រចាំឆ្នាំ ។ តាមផ្លូវគេឃើញយាយតាពូមីង កម្លោះក្រមុំ មេម៉ាយ ពោះម៉ាយ ក្រមុំសៅកែ ។ល។ នាំគ្នាដើរត្រសងស្លៀកពាក់ចំរុះពណ៌ស្រស់ឆើតឆាយ កាន់រែកទូលម្ហូបអាហារ ទៀនធូបផ្កាភ្ញីទឹកមុខញញឹមប្រិមប្រិយសំដៅទៅវត្ត ឯខ្លះក៏ធ្វើដំណើរត្រលប់មកពីវត្តវិញដែរ ។

នៅតាមផ្លូវដីក្នុងភូមិដែលមានភក់រអិលប៉ិប៉ុចប៉ាច់នោះមានរថយន្តទេសចរម៉ូតូរ៉ឺម៉ក គ្រប់ធុនរបស់អ្នកភ្នំពេញ និងអ្នកស្រុកគៀនស្វាយបើកបរទៅមក សន្សឹមៗដោយ

ខ្លាចរអិល ឬបាចខ្លាតភក់លើអ្នកដំណើរដែលត្រាច់ចរហូរហែតាមផ្លូវ ។

នាងសូណេត តុបតែងខ្លួនយ៉ាយផាម្ចងបៃតង និងអាវចាក់សសក់ខ្មៅរលើបប្រាស់ ស្នាដៃកាន់ចានស្រាក់រួមដំណើរជាមួយម្ដាយនាង និងមីងសុតម្ដាយសាវ៉ាន់ដែលនៅផ្ទះជិតខាងនាងត្រឡប់មកពីវត្តវិញ ។នាងដើរបោះជំហ៊ានយឺតៗអោនឈ្ងោកមើលភក់តាមផ្លូវ ខ្លាចរអិលជួលប្រឡាក់សំពត់ដីស្រស់ឆើតឆាយរបស់នាង ។ យូរៗម្ដងនាងងើយភក្រ្តឡើងបញ្ចេញសម្រស់វង់ភក្រ្តស្រទន់ ដូចផ្កាកូឡាប សមនិងរាងកាយល្មត់ល្មន់សាច់សរលោងស្រិល ធ្វើអោយកំលោះទាំងឡាយតាមលួចមើលនាងតាំងពីវត្ត រហូតនាងចេញពីវត្តមកផ្ទះវិញ ។

ពេលនោះ....ស្រាប់តែមានម៉ូតូបួនគ្រឿងបញ្ចេញសំលេងរ៉ោងៗពីចម្ងាយ ។អ្នកជិះសុទ្ធតែជាយុវជនកំពុងបញ្ចេញឫកច្រងេងច្រងាងសើចក្អាកក្អាយ បំបោលម៉ូតូមិនបង្អង់ល្បឿនកាត់ភក់បាចទឹកក្រខ្វក់ទៅលើអ្នកដំណើរ ដែលកំពុងដើរតាមផ្លូវ ។ ពួកគេសើចសប្បាយនៅពេលដែលឃើញអ្នកដំណើរ រត់គេចខ្លាចប្រឡាក់ភក់ដែលខ្ទាតចេញពីម៉ូតូរបស់គេ ។ ពេលពួកគេមកដល់ទន្ទឹមនិងនាងសូណេត យុវជនឥតសណ្ដាប់ធ្នាប់ទាំងនោះបានជិះបំពារទៅក្បែរនាង បណ្ដាលអោយនាងសូណេតភ្ញាក់គេចធ្លាក់ទៅក្នុងក្រលុកស្មៅក្បែរផ្លូវ ។ ភក់បានបាចចេញពីកង់ម៉ូតូ ទៅប្រលាក់សំពត់របស់នាង ។ នាងសូណេតខឹងខ្លាំងណាស់ បើកភ្នែកធំៗសម្លឹងមើលមនុស្សព្រហើនទាំងនោះ ។ មីងសុត និងមីងទៀងស្ទុះទៅជួយលើកនាងសូណេតហើយស្រែកស្ដីអោយអ្នកជិះម៉ូតូថា ៖

-ដូចជាជ្រុលពេកហើយ ! ជិះម៉ូតូជាន់មនុស្សទាំងរស់យ៉ាងនេះ !

(មីងសុតឧទានឡើងដោយខឹងខ្លាំងពេក) ។

-មនុស្សអីក៏អត់សុជីវធម៌ អត់ស្គាល់ខុសស្គាល់ត្រូវសោះ យ៉ាងនេះមានម៉ូតូជិះចង់បំបោលម៉េចមិនទៅបំពោលលើថ្នល់ជាតិអោយវាអស់ចិត្តអស់ចង់ទៅ ! មកបោល



អីផ្លូវភក់កណ្ដាលភូមិអ្នកស្រុកទៅវិញ !(មីងទៀងនិយាយបណ្ដើរសំឡក់ថ្ងៃ ទៅរកហ្វូងយុវជនទាំងនោះ)។

ក្រុមយុវជនពាលឈប់ម៉ូតូព័ទ្ធជុំវិញនារីរងគ្រោះ ។ យុវជនម្នាក់មានឧចំក្រអាញ់ដើរចេញពីម៉ូតូយ៉ាងលឿនសំដៅនាងសូណេត ហើយពោលទៅកាន់នាងសូណេតថា៖

-ខ្ញុំបានធ្វើអោយប្រឡាក់សំពត់អាវនាងឬ ? អូ ! គួរអោយអាណិតណាស់ ! សុំទោសណាអ្នកនាង ! ខ្ញុំសុំធានាជូននាងទៅផ្ទះ ! (នាយស្ការពោលរួចក៏ចាប់ទាញដៃនាងសូណេតអោយឡើងជិះម៉ូតូរបស់ខ្លួន ) ។ នាងសូណេតដកដៃនាងចេញរហ័ស



ពីជនពាល នាងថយក្រោយអោយម្ដាយនាង និងមីងសុតជួយ ។ មីងសុតស្ទុះមកពាំង មិនអោយនាយស្ការព្រហើននេះចូលជិតនាងសូណេតឡើយ ។ នាយស្ការពីរនាក់ទៀត ស្ទុះមកបំរុងចាប់នាងសូណេតដាក់ម៉ូតូ ឆាកប្រវ៉ាយប្រតប់គ្នាចាប់ផ្ដើម ។ មីងទ្បេង មីងសុតអោបនាងសូណេតជាប់ ។

-អាត្បិចាប់ឃាយពីរនាក់នោះចេញ !(សម្លេងយុវជនមាឌធំបញ្ជា) ឯអាខ្មៅ! ទៅយកកាំភ្លើងពីអាម៉ូផែនមកអោយអញ !

-បាទបងរាម !(នាយខ្មៅឆ្លើយរបៀបគោរពទៅរកនាយស្ការមាឌក្រអាញនេះ ហាក់ដូចចាត់ទុកនាយរាមនេះ ជាមេរៀមច្បងរបស់វាដូច្នោះ) ។

-អាម៉ូផែន ! បងរាមអោយអញមកយកកាំភ្លើងរបស់ឯង ! (នាយខ្មៅពោល ទៅកាន់យុវជនម៉ូផែនដែលអង្គុយលើម៉ូតូ បញ្ឆេះចាំរួចជាស្រេច)។

-ទេ ! អញមិនអោយទេ ! កាំភ្លើងនេះសំរាប់ការពារពេលមានអាសន្នមិនមែន យកមកអោយឯងប្រើទេ !(ម៉ូផែនប្រកែកមិនអោយ កាំភ្លើងទៅនាយខ្មៅ )។ នាយខ្មៅលូកដៃយ៉ាងរហ័សដកកាំភ្លើងពីចង្កេះខោនាយម៉ូផែន ។ ម៉ូផែលនិងម៉ូផែនដាក់ជន្ទល់ម៉ូតូហើយតាមដណ្ដើមកាំភ្លើងពីនាយខ្មៅមកវិញ ។ នាយខ្មៅយកកាំភ្លើងទៅភ្ជង់គំរាម មីងឡេង មីងសុត អោយថយចេញពីនាងសូណេត ។ មីងសុត ឃើញកាំភ្លើងភ័យហាមាត់ជង្រ្គង់ធ្លាក់កញ្ចុកថ្នាំក្ដុកទៅបី ។ មីងឡេងភ័យខ្លាំងជាងមីងសុតទៅទៀតស្រែកវ៉ាសឡើង :

-ជួយផង !! ៗ ចោរៗ !!

អាខ្មៅវាគ្រាន់តែផ្ជង់កាំភ្លើងដាក់មីងពីរនាក់នោះ តែវាពុំបានបាញ់ទេ ។ អាត្បិ និងនាយរាមប្រឹងប្រឡេះមីងឡេង មីងសុតពីនាងសូណេតតែមិនរបេះសោះ ។





អាត្បិចាប់ទាញចង្កេះឃាយសុត ដែលអោបនាងសូណេតជាប់ស្អិតនោះទាល់តែមីងទ្រាំមិនបានលេចនោមផ្លុះដាក់អាត្បិ ដែលនៅពីក្រោយខ្នងគាត់ អាត្បិភ្ញាក់ចំណាប់រអិលអុកគូថទៅលើភក់ទាញទាំងមីងសុត ដែលមានសំពត់ទទឹកជោកដោយទឹកមូត ផងនោះ ដួចចាប់គាត់អង្គុយសង្កត់លើពោះអាត្បិ ។ អាត្បិធ្វើមាត់ស្ញេញសាបកម្លាំង ដើយក្បួចខ្លួន ណាមួយភ័យនិងសម្រែកមីងឡេង ដែលស្រែកថាចោរៗនោះផង ។

អាខ្មៅយកកាំភ្លើងភ្ជង់មីងឡេងកុំអោយស្រែក មីងឡេងស្ទន់ពេកស្រែករឹតតែខ្លាំងចោរ !! ៗ ជួយផង ! ។

ម៉ូផែល និងម៉ូផែនមិនទាន់ដណ្ដើមកាំភ្លើងពីនាយខ្មៅផង ក៏រត់ទៅកាន់ម៉ូតូវិញ ព្រោះឃើញអ្នកស្រុកផ្អើលមកពីឆ្ងាយ ជាពិសេសមានរថយន្តមួយគ្រឿងបរមកដល់ទី